# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ០២៣ **គ.ជ.ប.** ស.ន.ល

# សេចក្ដីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ចំនួន **៨.៣៤២ រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ឱ្យបម្រើការងារនៅតាមគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានទទួលបន្ទុកដឹកនាំការងាររួម និងការងារហិរញ្ញវត្ថុ | ចំនួន ១ រូប |
| ២- អនុប្រធានជួយធ្វើការប្រធាន និងទទួលបន្ទុកលើការងារប្រតិបត្តិការ និងបច្ចេកទេស | ចំនួន ១ រូប |
| ៣- សមាជិកទទួលបន្ទុកលើការងាររដ្ឋបាល | ចំនួន ១ រូប |
| ៤- សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត | ចំនួន ១ រូប |
| ៥- សមាជិកទទួលបន្ទុកលើការងារអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ចំនួន ១ រូប ឬ២រូបឬ៣រូប |

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើ សូមអញ្ជើញទៅមើលសេចក្ដីជូនដំណឹងស្ដីពីការប្រឡងជ្រើសរើសចូលបម្រើការងារ និងលក្ខខណ្ឌជ្រើសរើសដែលនឹងបិទផ្សាយចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ នៅតាមគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងទីកន្លែងសាធារណៈក្នុងឃុំ សង្កាត់។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ នៅតាមលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងនៅតាមទីប្រមូលផ្ដុំ ក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត។

ការទទួលពាក្យសុំប្រឡងចូលបម្រើការងារនឹងធ្វើនៅតាមទីប្រមូលផ្ដុំ ក្រុង ស្រុក ខណ្ឌ ឬតាមទីកន្លែងដែលកំណត់ដោយ គធ.ខប ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្ដីជូនដំណឹងនេះ។

- ការចាប់ផ្ដើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមីនា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

**ប្រាជ្ញ ចន្ទ**

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ